# កម្ពុជា៖ អ្នកជំនាញការអង្គការសហប្រជាជាតិ ស្វាគមន៍ការដោះលែង និងអំពាវនាវឲ្យគោរពសេរីភាពនៃការបញ្ចេញមតិនៅក្នុងការបោះឆ្នោត នៅថ្ងៃខាងមុខ

ទីក្រុងហ្សឺណែវ (១៩ មីនា ២០១៣) – *អ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិស្ដីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា លោក សុរិយា ប្រាសាទ ស៊ូប៊ែឌី បានស្វាគមន៍ការដោះលែងលោក ម៉ម សូណង់ដូ នៅថ្ងៃនេះ និងការដោះលែងលោក កាន់ សុវណ្ណ និង លោក ទូច រាម នៅពេលឆាប់ៗខាងមុខ បន្ទាប់ពីសាលាឧទ្ធរណ៍កម្ពុជាបានសំរេចនៅថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៣។*

*"សាលាឧទ្ធរណ៍បានរកឃើញថា មិនមានភស្តុតាងគាំទ្រដល់ការចោទប្រកាន់ភាគច្រើន បន្ទាប់ ពីសាលាដំបូងបានកាត់ទោសឲ្យគាត់ជាប់ពន្ធនាគាររយៈពេល២០ឆ្នាំ ពីបទចោទប្រកាន់ផ្សេងៗគ្នារាប់ទាំងបទញុះញង់ពាក់ព័ន្ធនឹងកុប្បកម្ម" នេះបើតាមប្រសាសន៍របស់លោកស៊ូប៊ែឌី ។ "ការខ្វះចន្លោះធំៗមួយចំនួននៅក្នុងការជំនុំជម្រះក្ដីនេះពីខាងដើម ដែលបានគូសបញ្ជាក់ដោយគូសន្ទនាមួយចំនួនរបស់ខ្ញុំ ដែលខ្ញុំបានជួបនៅក្នុងអំឡុងពេលនៃដំណើរបេសកកម្មចុងក្រោយរបស់ខ្ញុំ មកកាន់ព្រះរាជាណាចក្រកម្ពុជាក្នុងខែធ្នូ ឆ្នាំ២០១២ មានប្រយោជន៍សំរាប់ការសំរេចសេចក្ដី របស់សាលាឧទ្ធរណ៍។*

*"ទោះជាយ៉ាងណាក៏ដោយ ខ្ញុំមានការសោកស្ដាយដោយសារថា ទោសមួយចំនួននៅតែមាននៅឡើយ ហើយបទចោទប្រកាន់ និងទោសថ្មីត្រូវបានបញ្ចូល ដោយមិនមានឱកាសសំរាប់ជនជាប់ចោទ ធ្វើការត្រៀមរៀបចំ ដើម្បីការពារខ្លួន" អ្នកជំនាញការសិទ្ធិមនុស្សបានសង្កត់ធ្ងន់ដូច្នេះ។*

*"ខ្ញុំបានតាមមើលករណីរបស់លោកម៉ម សូណង់ដូ យ៉ាងជិតដល់ ហើយខ្ញុំបានជួបជាមួយគាត់ផ្ទាល់នៅក្នុងពន្ធនាគារ កាលពីខែធ្នូកន្លងទៅនេះ ដើម្បីស្ដាប់ទស្សនៈផ្ទាល់ខ្លួនរបស់គាត់ អំពីចំណាត់ការករណីនេះ។ ទំនាក់ទំនងរវាងការចោទប្រកាន់លើលោកម៉ម សូណង់ដូ និងសេរីភាពនៃបញ្ចេញមតិក្នុងប្រទេសកម្ពុជា គឺជាក្ដីកង្វល់ចំពោះខ្ញុំ" អ្នករាយការណ៍ពិសេសបានមានប្រសាសន៍ដូច្នេះ។" ដូចដែលខ្ញុំបានកត់សំគាល់នៅក្នុងរបាយការណ៍ចុងក្រោយ * របស់ខ្ញុំ ដាក់ជូនក្រុមប្រឹក្សាសិទ្ធិមនុស្សថា សេរីភាពពិតប្រាកដក្នុងការបញ្ចេញមតិ គឺមានសារៈសំខាន់ជាសារវ័ន្ត ចំពោះសង្គមប្រជាធិបតេយ្យណាក៏ដោយដែលដំណើរការល្អ។*

*ដោយកត់សំគាល់ថា នេះគឺជាការពិត ជាពិសេស នៅក្នុងអំឡុងពេលនៃការបោះឆ្នោត ដូចជាការបោះឆ្នោតមួយដែលប្រទេសកម្ពុជាកំពុងត្រៀមរៀបចំ អ្នករាយការណ៍ពិសេស បានស្នើយ៉ាងទទូចដល់រាជរដ្ឋាភិបាល សង្គមស៊ីវិល អង្គការសហប្រជាជាតិ និងអ្នកផ្ដល់ជំនួយនានា សូមយក*

ចិត្តទុកដាក់ឃ្លាំមើលជាពិសេស ក្នុងការលើកកំពស់ និងការការពារសិទ្ធិសេរីភាពនៃការបញ្ចេញមតិ និងយោបល់ នៅក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រដែលនឹងមកដល់នៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៣។

(*) ដើម្បីឆែកមើលរបាយការណ៍ឆ្នាំ២០១២ របស់អ្នករាយការណ៍ពិសេស ដាក់ជូនក្រុមប្រឹក្សាសិទ្ធិមនុស្ស៖ http://www.ohchr.org/Documents/HRBodies/HRCouncil/RegularSession/Session21/A-HRC-21-63-Add1en.pdf

# (ចប់)

លោកសាស្ត្រាចារ្យ សុរិយា ប្រាសាទ ស៊ូប៊ែឌី ត្រូវបានក្រុមប្រឹក្សាសិទ្ធិមនុស្ស អ.ស.ប តែងតាំងជាអ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា ក្នុងខែមីនា ឆ្នាំ២០០៩។ ក្នុងនាមជាអ្នករាយការណ៍ពិសេស លោកមិនចំណុះរដ្ឋាភិបាល ឬអង្គការណាមួយឡើយ ហើយបំរើការក្នុងសមត្ថភាពបុគ្គលលោកផ្ទាល់ ។ បច្ចុប្បន្ន លោកគឺជាសាស្ត្រាចារ្យផ្នែកនីតិអន្តរជាតិ នៃសកលវិទ្យាល័យលីដស៍ ចក្រភពអង់គ្លេស។

សិទ្ធិមនុស្ស អ.ស.ប គេហទំព័រប្រទេស – កម្ពុជា
http://www.ohchr.org/EN/Countries/AsiaRegion/Pages/KHIndex.aspx

សំរាប់ព័ត៌មានបន្ថែម និង**ការសាកសួរព័ត៌មានផ្សេងៗ** សូមមេត្តាទាក់ទងមកឈ្មោះ Olga Nakajo តាមរយៈ ទូរស័ព្ទលេខ (+៤១ ២២ ៩២៨ ៩៣៤៨ / អ៊ីម៉េល onakajo@ohchr.org)

សំរាប់**ការសាកសួរព័ត៌មាន**ពាក់ព័ន្ធនឹងអ្នកជំនាញការឯករាជ្យដទៃទៀតរបស់ អ.ស.ប សូមមេត្តាទាក់ទងមកឈ្មោះ Xabier Celaya សិទ្ធិមនុស្ស អ.ស.ប – អង្គភាពព័ត៌មាន តាមរយៈទូរស័ព្ទលេខ (+៤១ ២២ ៩១៧ ៩៣៨៣ / អ៊ីម៉េល xcelaya@ohchr.org)

**សិទ្ធិមនុស្ស អ.ស.ប ស្វែងយល់ពីយើងតាមរយៈព័ត៌មានសង្គម ៖**
ហ្វេសប៊ុក៖ https://www.facebook.com/unitednationshumanrights
ទ្វីតធឺ៖ http://twitter.com/UNrightswire
ហ្គោហ្គើល៖ Google+ gplus.to/unitednationshumanrights
យូធូប៖ http://www.youtube.com/UNOHCHR
បរិយាយជាសាច់រឿង ៖ http://storify.com/UNrightswire
ដើម្បីឆែកមើលឧបសម្ព័ន្ធសិទ្ធិមនុស្សជាសកល៖ http://uhri.ohchr.org/en